# មេរៀនទី៦៩ បឹងទន្លេសាប

## អំណាន



បឹងទន្លេសាប ជាជម្រកត្រីនៃប្រទេសកម្ពុជា។

នៅរដូវវស្សា បឹងទន្លេសាបលាតសន្ធឹងល្វឹងល្វើយ។ បឹងនេះ មានព្រៃរនាមដុះជុំវិញដែលជាជម្រកសម្រាប់ត្រីពង។ បឹងទន្លេសាបសម្បូរត្រីទឹកសាបជាងគេលើពិភពលោក។ រៀងរាល់ឆ្នាំ ប្រជាជនយើងនេសាទត្រីបានច្រើនក្រៃលែង។ ពួកគេយកត្រីទាំងនោះសម្រាប់ធ្វើម្ហូបអាហារដូចជា ប្រហុក ផ្អក ត្រីងៀត ត្រីឆ្អើរ ។ល។ ផ្ទៃដីជុំវិញបឹងទន្លេសាប មានជីជាតិល្អណាស់សម្រាប់ដំណាំកសិកម្ម ពិសេសដំណាំស្រូវ។

LIVEWORKSHEETS

បឹងទន្លេសាប ជាប្រភពធនធានធម្មជាតិមួយយ៉ាងសំខាន់នៃប្រទេសកម្ពុជា។

I. ចូរកូនជ្រើសរើសចម្លើយឱ្យបានត្រឹមត្រូវ។

១.តើបឹងទន្លេសាបមានលក្ខណៈដូចម្តេច?

ក.ធំល្មម ខ.តូចចង្អៀត គ.ធំល្វឹងល្វើយ

២.តើនៅជុំវិញបឹងទន្លេសាបមានអ្វីខ្លះ?

ក.ព្រៃលិចទឹក ខ.ព្រៃរនាម គ.ព្រៃកោងកាង

៣.តើគេយកត្រីមកធ្វើអ្វីខ្លះ?

ប្រហុក ត្រីងៀត សាច់គោ ត្រីឆ្អើរ បន្លែ ផ្អក

៤.ហេតុអ្វីបានជាដំណាំនៅជុំវិញបឹងទន្លេសាបផ្តល់ផលបានច្រើន?

ក.មានទឹកប្រើច្រើនគ្រប់គ្រាន់ ខ.ដីមានជីជាតិល្អ

II. ចូរជ្រើសរើសពាក្យក្នុងប្រអប់ ទៅបំពេញល្បះឱ្យបានត្រឹមត្រូវ។

| កសិកម្ម | ទឹកសាប | ជុំវិញ | ល្វឹងល្វើយ | ជម្រក |
|---|---|---|---|---|

១. បឹងទន្លេសាបជា..................ត្រីនៃប្រទេសកម្ពុជា។

២. នៅរដូវវស្សាបឹងទន្លេសាបលាតសន្ធឹង...................។

LIVEWORKSHEETS

៣.  បឹងទន្លេសាបសម្បូរត្រី..................ជាងគេលើពិភពលោក។

៤.  ផ្ទៃដី.................បឹងទន្លេសាបមានដីជាតិល្អណាស់សម្រាប់

ដំណាំ....................ពិសេសដំណាំស្រូវ។

III.  ចូរជ្រើសរើសពាក្យក្នុងប្រអប់ ទៅបំពេញល្បះឱ្យបានត្រឹមត្រូវ។

| | |
|---|---|
| ១.បឹងទន្លេសាបជាជង្រុកត្រី | ក.ជាងគេលើពិភពលោក។ |
| ២.បឹងទន្លេសាបជាប្រភពធនធាន | ខ.នៃប្រទេសកម្ពុជា។ |
| ៣.បឹងនេះមានព្រៃរនាមដុះជុំវិញ | គ.ធម្មជាតិមួយយ៉ាងសំខាន់ នៃប្រទេសកម្ពុជា។ |
| ៤.បឹងទន្លេសាបសម្បូរត្រីទឹលសាប | ឃ.ដែលជាជម្រកសម្រាប់ ត្រីពង។ |

LIVEWORKSHEETS

LIVEWORKSHEETS